# ពិធីសម្ពោធជាផ្លូវការនៃ
# យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ២០១៤-២០១៨
# ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤

## សុន្ទរកថាបិទរបស់ ឯកឧត្តម ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

*ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី*

*លោក ក្លែរ វ៉ាន់ ដឺ វ៉ារ៉េន អ្នកសម្របសម្រួលអង្គការសហប្រជាជាតិ ប្រចាំព្រះរាជាណាចក្រកម្ពុជា*

*លោក អេរិក ស៊ីដវីក ប្រធាន ធនាគារអភិវឌ្ឍន៍អាស៊ី ប្រចាំប្រទេសកម្ពុជា*

*លោកបណ្ឌិត អាឌីការី នាយកប្រតិបត្តិ កម្មវិធីពង្រឹងក្របខ័ណ្ឌសមាហរណកម្ម (EIF)*

*លោក ប៊ីនហាដ ឆ្លាចថឺរ មន្ត្រីប្រតិបត្តិ អង្គការ UNOPS*

*សមាជិក សមាជិកា អង្គទូតនៅក្នុងព្រះរាជាណាចក្រកម្ពុជា*

*ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ លោក លោកស្រី!*

***

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណជាថ្មីម្តងទៀតដល់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ដែលសម្តេចបានធ្វើជាអធិបតីក្នុងពិធីបើកកិច្ចប្រជុំកាលពីព្រឹកមិញនេះ ព្រមទាំងបានសង្កត់ធ្ងន់ទៅលើតួនាទីដ៏សំខាន់ដែលវិស័យពាណិជ្ជកម្មរបស់កម្ពុជាត្រូវបំពេញ ដើម្បីអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីបីរបស់រាជរដ្ឋាភិបាល។

ខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះ ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ លោក លោកស្រី ដែលបានចូលរួមនៅក្នុងកិច្ចប្រជុំនាព្រឹកនេះ។

ចុងក្រោយ អនុញ្ញាតឲ្យខ្ញុំថ្លែងអំណរគុណឯកឧត្តម ប៉ាន សូរស័ក្តិ ដែលបានផ្តល់បទបង្ហាញអំពីចំណុចសំខាន់ៗមួយចំនួននៃ*យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ២០១៤-២០១៨* ព្រមទាំង*ផែនទីបង្ហាញផ្លូវនៃអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម* ដែលភ្ជាប់ជាមួយយុទ្ធសាស្ត្រនេះ។

***

ដូចដែល**សម្តេចតេជោ**បានបញ្ជាក់កាលពីព្រឹកមិញមកហើយ ឯកសារទាំងពីរនេះ ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល នឹងក្លាយទៅជាផែនការលម្អិតរួមមួយសម្រាប់អនុវត្តដោយរាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ ដែលរួមមានវិស័យឯកជន និងដៃគូអភិវឌ្ឍន៍នៅកម្ពុជា នៅក្នុងវិស័យពាណិជ្ជកម្មក្នុងបណ្តាឆ្នាំខាងមុខនេះ។ *ផែនទីបង្ហាញផ្លូវនៃអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម* បានផ្តល់នូវអនុសាសន៍ និងសំណើសំខាន់ៗជាច្រើនសម្រាប់កំណែទម្រង់។ ការងារដែលត្រូវធ្វើនាពេលខាងមុខគឺជាភារកិច្ចរបស់រាជរដ្ឋាភិបាល ដោយមានការគាំទ្រពីវិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ដើម្បីស្វែងរកវិធីផ្សេងៗក្នុងការអនុវត្តអនុសាសន៍ និងសំណើទាំងនេះ។

ក្រសួងពាណិជ្ជកម្ម គឺជាប្រធានដឹកនាំ *អនុគណៈកម្មាធិការស្តីពីពាណិជ្ជកម្ម និងការវិនិយោគដែលទាក់ទងនឹងពាណិជ្ជកម្ម* និង*អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម*។ ក្នុងនាមជាប្រធាន ខ្ញុំមានបំណងខិតខំប្រឹងប្រែងឲ្យអស់ពីសមត្ថភាពរបស់ខ្ញុំ ដើម្បីជួយជំរុញការអនុវត្តនូវអនុសាសន៍ជាច្រើនដែលមាននៅក្នុងផែនទីបង្ហាញផ្លូវអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម។ អនុសាសន៍ជាច្រើនក្នុងចំណោមអនុសាសន៍ទាំងនោះ ត្រូវបានពិភាក្សា និងពិនិត្យឡើងវិញយ៉ាងល្អិតល្អន់ ជាមួយមន្ត្រីនៅក្នុងរាជរដ្ឋាភិបាល តំណាងវិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ក្នុងអំឡុងពេលរៀបចំ *យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ២០១៤-២០១៨*។

ទោះបីជាយ៉ាងណាក្តី វាជាការច្បាស់ណាស់ដែលថា ការអនុវត្តផែនការលម្អិតប្រកបដោយមហិច្ឆតានេះមិនអាចអនុវត្តតែ ក្រសួងពាណិជ្ជកម្មមួយបានទេ។ យើងត្រូវការការចូលរួមឲ្យបានសកម្ម ពីភាគីពាក់ព័ន្ធទាំងអស់ រួមទាំង ក្រសួងពាក់ពន្ធ អ្នកតំណាងវិស័យឯកជន ប្រតិបត្តិករ វិនិយោគិន និងដៃគូ

អភិវឌ្ឍន៍។ នៅក្នុងរយៈពេលប៉ុន្មានសប្តាហ៍ខាងមុខនេះ ខ្ញុំទន្ទឹងរង់ចាំពិនិត្យឡើងវិញ ជាមួយអ្នកទាំងអស់គ្នា អំពីថាតើយើងអាចធ្វើការកែលម្អយន្តការ *អនុគណៈកម្មការនេះ* និង*អភិក្រមគ្រប់ដណ្តប់លើវិស័យពាណិជ្ជកម្ម* បានដូចម្តេចខ្លះ ដើម្បីជួយយើងត្រួតពិនិត្យតាមដានមើលវឌ្ឍនភាពរួមរបស់យើងធៀបនឹងគោលដៅចំណុច រួមទាំងការផ្សារភ្ជាប់ការងាររបស់យើងទៅនឹងក្រុមការងារនានា ដែលបានបង្កើតឡើងដោយរាជរដ្ឋាភិបាល ដើម្បីត្រួតពិនិត្យតាមដានមើលការអនុវត្តយុទ្ធសាស្រ្តចតុកោណដំណាក់កាលទីបី។

***

ជាការឆ្លើយតបដំបូងមួយទៅសំណើខ្លះ ក្នុងចំណោមសំណើទាំងឡាយដែលបានលើកឡើងនៅក្នុង *យុទ្ធសាស្រ្តសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ២០១៤-២០១៨* ក្រសួងពាណិជ្ជកម្មបានចាត់វិធានការមួយចំនួនរួចទៅហើយ នៅក្នុងផ្នែកផ្សេងៗដែលស្ថិតនៅក្រោមការទទួលខុសត្រូវដោយផ្ទាល់របស់ខ្លួន។ វិធានការទាំងនោះ រួមមាន៖

1. ស្វ័យប្រវត្តិកម្មដំណើរការធុរកិច្ចសំខាន់ៗរបស់ក្រសួងពាណិជ្ជកម្ម។ ដូចដែលអ្នកទាំងអស់គ្នានៅចាំបានថា បន្ទាប់ពីមានកិច្ចពិគ្រោះយោបល់ ជាមួយភាគីពាក់ព័ន្ធនៅក្នុងវិស័យឯកជននៅចុងខែវិច្ឆិកា មក ខ្ញុំបានប្រកាសថា ក្រសួងពាណិជ្ជកម្មនឹងធ្វើការពន្លឿនការសម្រួល និងស្វ័យប្រវត្តិកម្មដំណើរការសំខាន់ៗមួយចំនួន ផ្សារភ្ជាប់នឹងការនាំចេញ រួមទាំង ការរៀបចំឲ្យមានការចេញវិញ្ញាបនបត្រប្រភពដើម តាមអ៊ីនធើណិត ក៏ដូចជាដំណើរការចុះបញ្ជីក្រុមហ៊ុន។ ឥឡូវនេះ ដំណើរការនេះកំពុងរៀបចំ ទៅយ៉ាងរលូន។ ខ្ញុំក៏បានប្រកាសនៅក្នុងពេលនោះដែរថា កាំកុងត្រូលនឹងត្រូវបានធ្វើកំណែទម្រង់។ ដំណើការនោះកំពុងតែរំកិលទៅមុខយ៉ាងរហ័ស។
2. ទាក់ទងទៅនឹងវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវពាណិជ្ជកម្ម ខ្ញុំកំពុងតែជំរុញធ្វើយ៉ាងណាឲ្យវិទ្យាស្ថាននេះមានដំណើរការ។ យើងបានរៀបចំទីកន្លែងមួយរួចជាស្រេច សម្រាប់វិទ្យាស្ថាននេះ។ យើងកំពុងតែស្វែងរកជំនួយសម្រាប់រៀបចំវិទ្យាស្ថាននេះ និងបង្កើតការបណ្តុះបណ្តាល ព្រមទាំងបានធ្វើការពិភាក្សាជាមួយអង្គការអន្តរជាតិពាក់ព័ន្ធផ្សេងៗ អំពីថាតើពួកគេអាចជួយយើងដូចម្តេចខ្លះ ទាក់ទងទៅនឹងការរៀបចំកម្មវិធីសិក្សា និងគ្រូបង្គោលសម្រាប់កម្មវិធីបណ្តុះបណ្តាលនេះ។

3. ចំពោះការជំរុញការនាំចេញ ខ្ញុំបានសម្រេចបង្កើនធនធានរបស់ក្រសួងសម្រាប់ជំរុញការនាំចេញ និងរៀបចំមុខងារនេះឡើងវិញ។ នៅក្នុងរចនាសម្ព័ន្ធថ្មីរបស់ក្រសួង ការជំរុញពាណិជ្ជកម្ម នឹងក្លាយទៅជាអគ្គនាយកដ្ឋានមួយ លែងជា នាយកដ្ឋានដូចបច្ចុប្បន្នទៀតហើយ។ សកម្មភាពជំរុញការនាំចេញរបស់យើង នឹងត្រូវបានពង្រីក ពង្រឹង និងដឹកនាំកាន់តែប្រសើរជាងមុន សំដៅកែលម្អប្រសិទ្ធភាពការងារ។ យើងសង្ឃឹមថា យើងនឹងមានសមត្ថភាពចូលរួមជាមួយ *បណ្តាញអង្គការជំរុញពាណិជ្ជកម្មសកល* ក្នុងពេលឆាប់ៗខាងមុខនេះ។
4. អំពីគោលនយោបាយពាណិជ្ជកម្ម។ *យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា* បានចង្អុលបង្ហាញយ៉ាងត្រឹមត្រូវថា ឥឡូវនេះ យើងមានវិសាលភាព ច្រើនណាស់សម្រាប់ផលិតនៅក្នុងប្រទេសកម្ពុជា នូវវត្ថុធាតុដើមខ្លះដែលឧស្សាហកម្មនាំចេញសំលៀកបំពាក់ ស្បែកជើង និងទោចក្រយាន ត្រូវការ។ ការផលិតវត្ថុធាតុដើមនៅក្នុងប្រទេសកម្ពុជា នឹងបង្កើនអត្ថប្រយោជន៍យ៉ាងច្រើន ដែលកម្ពុជាទទួលបានពីឧស្សាហកម្មនាំចេញរបស់ខ្លួន។ នៅក្នុងរយៈពេលប៉ុន្មានខែខាងមុខនេះ យើងនឹងពិនិត្យមើលវិធានការនានាដែលត្រូវអនុវត្តដើម្បីលើកទឹកចិត្តដល់ការផលិតគ្រឿងបន្លាស់ និងវត្ថុធាតុដើមក្នុងប្រទេស សម្រាប់ផ្គត់ផ្គង់ដល់អ្នកនាំចេញរបស់យើង។

ទាំងនេះគឺជាវិធានការមួយចំនួនដែលយើងបានចាត់ឡើង ឬកំពុងពិចារណាអនុវត្ត។ ដូចដែលបានបញ្ជាក់រួចមកហើយ ខ្ញុំមានគម្រោងពិនិត្យឡើងវិញ ជាមួយសមភាគីរបស់ខ្ញុំនៅក្នុងក្រសួងដទៃទៀត អំពីថាតើយើងអាចជំរុញបន្ថែមទៀតដូចម្តេចខ្លះចំពោះអនុសាសន៍ផ្សេងៗទៀត។ ប៉ុន្តែ ជាថ្មីម្តងទៀត យើងត្រូវតែពង្រឹងភាពជាដៃគូរបស់យើង ជាមួយភាគីពាក់ព័ន្ធក្នុងវិស័យឯកជន ដើម្បីធានាថា ពួកគេចូលរួមយ៉ាងពេញលេញផងដែរ នៅក្នុងគម្រោងការណ៍ប្រកបដោយមហិច្ឆតាមួយនេះ។

***

យើងក៏ត្រូវការការចូលរួមជាបន្តពីដៃគូអភិវឌ្ឍន៍របស់យើងដែរ។ កិច្ចខិតខំប្រឹងប្រែងពីក្រោយ *យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ២០១៤-២០១៨* គឺជាឧទាហរណ៍ដ៏ខ្លាំងមួយនៃការធ្វើការរួមគ្នារវាងរាជរដ្ឋាភិបាល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ឆ្ពោះទៅរកគោលដៅរួមមួយ។ ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះការគាំទ្រដែលផ្តល់ដោយកម្មវិធីពង្រឹងក្របខ័ណ្ឌសមាហរណកម្ម ធនាគារអភិវឌ្ឍន៍អាស៊ី, UNDP និងធនាគារពិភពលោក នៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះ។ ខ្ញុំដឹងថា អ្នកទាំងអស់គ្នា ប្តេជ្ញាចិត្តជំរុញការអនុវត្តដោយប្រសិទ្ធភាព នូវផែនទីបង្ហាញផ្លូវអភិក្រមគ្រប់ដណ្តប់វិស័យពាណិជ្ជកម្មថ្មីនេះ។

ថ្ងៃខានស្អែកនេះ យើងនឹងប្រកាសដាក់ឲ្យអនុវត្តកម្មវិធី CEDEP ទី II (កម្មវិធីពិពិធកម្ម និងពង្រីកការនាំចេញរបស់កម្ពុជា) ដោយមានការគាំទ្រផ្នែកថវិកាពីកម្មវិធីពង្រឹងក្របខ័ណ្ឌសមាហរណកម្ម និងដៃគូអភិវឌ្ឍន៍ដទៃទៀត ដែលចូលរួមតាមរយៈអនុគម្រោងខ្លះ ដែលមាននៅក្នុងកម្មវិធីថ្មីនេះ។ កម្មវិធីនេះគឺជាការបន្ថែមទៅលើកម្មវិធី CEDEP ទី I ដែលផ្តល់ហិរញ្ញប្បទានដោយកម្មវិធីពង្រឹងក្របខ័ណ្ឌសមាហរណកម្ម ផងដែរ។

កម្មវិធី CEDEP I និង CEDEP II គឺជាឧទាហរណ៍យ៉ាងសំខាន់នៃជំនួយដែលផ្តោតចំគោលដៅ ដើម្បីជួយកម្ពុជា កសាងសមត្ថភាពរបស់ខ្លួននៅក្នុងផ្នែកជាអាទិភាពសំខាន់ៗនៃពាណិជ្ជកម្ម ព្រមទាំងជួយសម្រេចបានគោលដៅចំណុចខ្លះរបស់រាជរដ្ឋាភិបាល។

កម្មវិធី CEDEP ទី I ផ្តោតលើវិស័យសូត្រ និងអង្ករ។ ដូចដែល**សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានបញ្ជាក់មកហើយ ការនាំចេញអង្កររបស់យើង បាននឹងកំពុងកើនឡើងយ៉ាងរហ័ស។ ដោយសារតែការគាំទ្រពីកម្មវិធី CEDEP ទី I អ្នកនាំចេញអង្កររបស់យើង កំពុងតែបង្កើនវត្តមាននៅក្នុងទីផ្សារ និងវេទិកាអន្តរជាតិកាន់តែច្រើនឡើង។ សម្រាប់រយៈពេលពីរឆ្នាំបន្តបន្ទាប់ ដោយមានការខិតខំធ្វើការ និងការគាំទ្រលើការជំរុញដ៏ឆ្លាតវៃពីកម្មវិធី CEDEP ទី I ម្ចាស់រោងម៉ាស៊ីនកិនស្រូវកម្ពុជា បានទទួលនូវការទទួលស្គាល់ថាជាអង្ករដែលល្អបំផុតក្នុងពិភពលោក។

កម្មវិធី CEDEP ទី II នឹងជួយយើង ផ្តោតការគាំទ្រទៅលើការនាំចេញផលិតផលជលផល និងដំឡូងមី ក៏ដូចជា ការអភិវឌ្ឍជំនាញសម្រាប់វិស័យទេសចរណ៍ដ៏សំខាន់។

ខ្ញុំសង្ឃឹមថា យើងអាចសំឡឹងទៅលើកម្មវិធី CEDEP ទី III ដែលនឹងជួយយើងផ្តល់ជំនួយបន្ថែមទៀតដល់វិស័យជាអាទិភាពខ្លះ ឬបញ្ហានានាដែលបានកំណត់នៅក្នុង *យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ២០១៤-២០១៨* ។ ខ្ញុំទន្ទឹងរង់ចាំជួបឯកឧត្តម លោកជំទាវ លោក លោកស្រីខ្លះនៅថ្ងៃខានស្អែកម្តងទៀត ក្នុងពិធីប្រកាសដាក់ឲ្យអនុវត្តកម្មវិធី CEDEP ទី II ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណជាថ្មីម្តងទៀត ដល់ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ដែលបានចូលរួមជាមួយយើងខ្ញុំនៅព្រឹកនេះ និងសូមប្រសិទ្ធពរជូនឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ សូមទទួលបាននូវព្រះពុទ្ធពរទាំងបួនប្រការ គឺ៖ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។